# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃចន្ទ ទី៥ ខែតុលា ឆ្នាំ២០១៥

យើងខ្ញុំទាំងអស់គ្នាជាប្រជាពលរដ្ឋមកពីសហគមន៍នានានៅរាជធានីភ្នំពេញ និងខេត្ត ក្រុង ជាជនរងគ្រោះដោយសារការបណ្តេញចេញដោយបំពានពីលំនៅដ្ឋាន និងដីធ្លី។

## សូមគោរពជូន
## សម្តេចអគ្គមហាពញាចក្រី ហេង សំរិន
## ប្រធានរដ្ឋសភាជាតិ

អង្គការសហប្រជាជាតិបានកំណត់យករៀងរាល់ថ្ងៃចន្ទសប្តាហ៍ទីមួយ នៃខែតុលាជារៀងរាល់ឆ្នាំ សម្រាប់ប្រារព្ធទិវាលំនៅដ្ឋានពិភពលោក ក្នុងគោលបំណងជំរុញដល់រដ្ឋភាគីនីមួយៗ ធានានូវសិទ្ធិមានលំនៅដ្ឋានជូនប្រជាពលរដ្ឋដូចមានចែងក្នុងច្បាប់ជាតិ និងអន្តរជាតិ។ ការប្រារព្ធទិវាលំនៅដ្ឋានពិភពលោកនេះ ក៏មានគោលបំណងរំលឹកដល់ពិភពលោកទាំងមូលថា មនុស្សជាតិទាំងអស់មានកាតព្វកិច្ច និងការទទួលខុសត្រូវចំពោះសិទ្ធិជាមូលដ្ឋាននៃការទទួលបានលំនៅដ្ឋានសមរម្យ។

នៅក្នុងខណៈនេះ មានប្រជាពលរដ្ឋរាប់រយលាននាក់នៅលើពិភពលោកកំពុងរងការគំរាមកំហែង និងរស់នៅក្នុងស្ថានភាពដ៏លំបាក ដោយសារតែការវិនិយោគធំៗ (ដីសម្បទានសេដ្ឋកិច្ច) ការរំលោភយកដីធ្លីពីអ្នកមានអំណាច បញ្ហាសង្គម សេដ្ឋកិច្ច ការរើសអើងពូជសាសន៍ សង្គ្រាម និងគ្រោះធម្មជាតិជាដើម។

ប្រជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញច្រើនជាង ១០ភាគរយ ត្រូវបានជម្លៀសចេញពីលំនៅដ្ឋានរបស់ខ្លួនក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ហើយពួកគាត់កំពុងរស់នៅក្នុងតំបន់ក្រីក្រជាមួយជីវភាពលំបាក។ ប្រជាពលរដ្ឋទាំងនោះត្រូវបានជម្លៀសចេញពីលំនៅដ្ឋានរបស់ខ្លួនក្រោមហេតុផលដើម្បីធ្វើការអភិវឌ្ឍ កែលម្អសោភ័ណ្ឌភាពទីក្រុងការរៀបចំសណ្តាប់ធ្នាប់ សន្តិសុខ និងសុវត្ថិភាពសង្គម។ ប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុងបានក្លាយជាជនរងគ្រោះ ខ្លាំងជាងគេនៅពេលដែលមានការអភិវឌ្ឍក្រោមហេតុផលទាំងនេះ។ ពួកយើងជាម្ចាស់ផ្ទះ ជាម្ចាស់ដីមិនទទួលបានផលអ្វីពីការអភិវឌ្ឍ តែត្រូវបានគេបង្ខំឱ្យចាកចេញពីលំនៅដ្ឋាន របស់ខ្លួនទៅរស់នៅក្នុងតំបន់ឆ្ងាយពីទីក្រុង ឬនៅតំបន់ជាយក្រុងដែលមិនទាន់មានសេវា សាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់នៅឡើយ។ ជារឿយៗតំបន់ដែលពួកយើងត្រូវបានជម្លៀសទៅនោះ នៅឆ្ងាយពីកន្លែងប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកយើង ហើយវាបានក្លាយជាឫសគល់ដ៏ធំមួយនៃភាពក្រីក្រតោកយ៉ាក។

ជាក់ស្តែង កន្លងមកក្នុងរាជធានីភ្នំពេញ ក៏ដូចជានៅតំបន់ជនបទមួយចំនួនក្នុងប្រទេសកម្ពុជា ពួកយើង បានយល់កាន់តែច្បាស់អំពីឫសគល់ពិតប្រាកដនៃភាពក្រីក្រដោយសារការជម្លៀសចេញ

ដោយបែបនេះ។ ពួកយើងជាប្រជាពលរដ្ឋទាំងនៅក្នុងទីក្រុង និងជនបទបាន និងកំពុងក្រោកឈរឡើងដើម្បីទាមទារឱ្យមានការអភិវឌ្ឍទីក្រុង និងប្រទេសជាតិប្រកបដោយតម្លាភាព សមភាព និងយុត្តិធម៌។ ប៉ុន្តែជាអកុសល ការខិតខំប្រឹងប្រែងក្រោកឈរធ្វើការទាមទារនេះ តែងតែត្រូវបានអាជ្ញាធរ និងមន្ត្រីរាជរដ្ឋាភិបាលដែលពាក់ព័ន្ធមួយចំនួនបានព្យាយាមទប់ស្កាត់ គំរាមកំហែង និងពេលខ្លះបានឈានទៅដល់ការបង្កហិង្សាមានរបួសស្នាម និងចាប់ដាក់ពន្ធនាគារ។ កន្លងមក អ្នកតស៊ូមតិម្ចាស់ផ្ទះ ឬដីមួយចំនួនត្រូវបានចាប់ខ្លួន ឃាត់ខ្លួន និងឃុំខ្លួនក្នុងពន្ធនាគារដោយអយុត្តិធម៌បំផុត។

ម៉្យាងវិញទៀត កន្លងមក រាជរដ្ឋាភិបាល សាលារាជធានីភ្នំពេញ ខេត្តក្រុង នានាបានរៀបចំគម្រោងអភិវឌ្ឍន៍ដោយមិនបានប្រឹក្សាយោបល់ពេញលេញជាមួយយើងខ្ញុំជាប្រជាពលរដ្ឋក្រីក្រ និងជាជនរងផលប៉ះពាល់ទេ ផ្ទុយទៅវិញ ពួកយើងខ្ញុំត្រូវបានគំរាម កំហែង និងបង្ខំឱ្យចាកចេញដោយមិនមានសំណង ឬមិនផ្តល់សំណងឱ្យសមរម្យឡើយ។ ដោយមើលឃើញរូបភាពមិនប្រក្រតីទាំងនេះ យើងខ្ញុំជាប្រជាពលរដ្ឋរស់នៅក្នុងទីក្រុង និងជនបទទទួចស្នើសុំ សម្តេចប្រធានរដ្ឋសភាជាតិ មេត្តាជ្រាប និងជួយដោះស្រាយសេចក្តីត្រូវការពិតប្រាកដរបស់យើងខ្ញុំ។

ក្នុងឱកាសអបអរសាទរទិវាលំនៅដ្ឋានពិភពលោកលើកទី៣០នេះ យើងខ្ញុំទាំងអស់គ្នាទទូចសុំ សម្តេចប្រធានរដ្ឋសភាជាតិ ជំរុញឱ្យរាជរដ្ឋាភិបាលគោរព និងការពារសេចក្តី ថ្លៃថ្នូររបស់យើងខ្ញុំជាប្រជាពលរដ្ឋក្រីក្រ និងជាជនរងផលប៉ះពាល់ដោយសារដីធ្លី និងលំនៅដ្ឋានទាំងអស់។ យើងខ្ញុំមិនជំទាស់ចំពោះការអភិវឌ្ឍទេ ប៉ុន្តែពួកយើងត្រូវតែទទួលបានផលប្រយោជន៍ពីគម្រោងអភិវឌ្ឍន៍ទាំងនោះផងដែរ។

នាឱកាសទិវាលំនៅដ្ឋានពិភពលោកឆ្នាំ២០១៥នេះដែរ យើងខ្ញុំទាំងអស់គ្នាចង់ឱ្យសាធារណៈជន រដ្ឋសភាជាតិ អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងស្ថាប័នពាក់ព័ន្ធនានានៃរាជរដ្ឋាភិបាលកម្ពុជាមេត្តាទទួលស្គាល់ និងអនុវត្តឱ្យបាននូវសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យទាំងជនបទ និងទីក្រុងដើម្បី *ឱ្យមានការអភិវឌ្ឍគឺសម្រាប់ទាំងអស់គ្នា និងបញ្ឈប់នូវរាល់ការបណ្តេញចេញដោយបង្ខំ ការប្រើអំពើហិង្សាលើប្រជាពលរដ្ឋ និងបញ្ឈប់ប្រើប្រាស់ប្រព័ន្ធតុលាការ គាបសង្កត់ប្រជាពលរដ្ឋ។*

<u>ឈ្មោះ សហគមន៍ និងអង្គការសង្គមស៊ីវិលខាងក្រោម</u>៖

1. សហគមន៍ទួលសង្កែបី
2. សហគមន៍មានជ័យស្ត្រីអភិវឌ្ឍន៍
3. សហគមន៍សាមគ្គីមានជ័យថ្មី
4. សហគមន៍សន្សំប្រាក់ដើម្បីអភិវឌ្ឍន៍
5. សហគមន៍ ស្ត្រីសាមគ្គីមានជ័យ
6. សហគមន៍សុវណ្ណភូមិមានជ័យ
7. សហគមន៍ស្ទឹងមាសមានជ័យ
8. សហគមន៍ស្ទឹងប្រាក់មានជ័យ

9. សហគមន៍ព្រះច័ន្ទក្រហម
10. សហគមន៍មានជ័យស្ត្រីអភិវឌ្ឍន៍
11. សហគមន៍អភិវឌ្ឍន៍ថ្មី
12. សហគមន៍ខ្វា
13. សហគមន៍ព្រែកតាគង់
14. សហគមន៍ភូមិ២
15. សហគមន៍ភូមិ១៧
16. សហគមន៍ភូមិ២២
17. សហគមន៍តាង៉ូវ
18. សហគមន៍បូរីកីឡា
19. សហគមន៍ថ្មគោល
20. សហគមន៍បឹងឈូកអេ
21. សហគមន៍គៀនឃ្លាំង
22. សហគមន៍ព្រែកតាសេក
23. សហគមន៍ព្រែកលៀប
24. សហគមន៍ផ្លូវជាតិលេខ៦
25. សហគមន៍អេស អូ អេស
26. សហគមន៍បូរីកីឡា ៣មករា
27. សហគមន៍ជ្រោយចង្វារ
28. សហគមន៍បឹងឈូក
29. សហគមន៍ភ្នំបាត
30. សហគមន៍ព្រែកតានូ
31. សហគមន៍សាមគ្គី
32. សហគមន៍១០៥
33. សហគមន៍១០៤
34. សហគមន៍វត្តប្រយូរវង្ស
35. សហគមន៍ពេទ្យលោកសង្ឃ
36. សហគមន៍ពញពន្ធ
37. សហគមន៍បឹងត្របែក
38. សហគមន៍បឹងកក់
39. សហគមន៍ភូមិ២៣
40. សហគមន៍ផ្លូវរទេះភ្លើង

41. សហគមន៍ទួលសង្កែអេ
42. សហគមន៍ត្រពាំងអញ្ចាញ
43. សហគមន៍អតីតបឹងកក់
44. សហគមន៍សាមគ្គី៤
45. សហគមន៍ជ័យជំនះ
46. សហគមន៍ត្រពាំងរាំងចាស់
47. សហគមន៍ទួលរកាកោះ
48. សហគមន៍ឡកំបោរ
49. សហគមន៍ភូមិអណ្តូង១
50. សហគមន៍ខ្មែរលើ
51. សហគមន៍សែនរីករាយ
52. សហគមន៍សែនសប្បាយ
53. សហគមន៍សំពោងមានជ័យ
54. សែនសុខភូមិ៥
55. សហគមន៍ទួលគោក
56. សហគមន៍ផ្សារតូចអា
57. សហគមន៍និរោធបឹងឈូក
58. សហគមន៍កោះនរា
59. សហគមន៍ព្រៃសាលា
60. សហគមន៍វាយបៀលឌឹង
61. សហគមន៍ស្វាយចេកថ្មី
62. សហគមន៍ក្រោលគោ
63. សហគមន៍៩២
64. សហគមន៍ឆេកូ
65. សហគមន៍បុរីមិត្តភាព
66. សហគមន៍ទំនប់២
67. សហគមន៍ចំរើន
68. សហគមន៍ផលអណ្តែត
69. សហគមន៍វាលស្បូវ
70. សហគមន៍ក្តីតាកុយ
71. សហគមន៍ឬស្សីស្រស់
72. សហគមន៍ស្ត្រីក្រីក្រក្រុម១៣

73. សហគមន៍កុមារក្រីក្រ
74. សហគមន៍ទំនប់៣
75. សហគមន៍ភ្នំពេញថ្មី
76. សហគមន៍កសិករ
77. សហគមន៍ស្ត្រីគោកឃ្លាំង
78. សហគមន៍ទឹកថ្លា
79. សហគមន៍ស្ត្រីទឹកថ្លា
80. សហគមន៍ឆេកូថ្មី
81. សហគមន៍ស្ត្រីរុងរឿង
82. សហគមន៍បុរីសន្តិភាព
83. សហគមន៍បុរីដើមស្រល់
84. សហគមន៍ស្ត្រីឃ្លាំងសាំង
85. សហគមន៍រួមមិត្ត
86. សហគមន៍បាគូអភិវឌ្ឍន៍
87. ក្រចេះ
88. ក្រុងព្រះសីហនុ
89. ពោធិសាត់
90. កំពង់ស្ពឺ
91. ត្បូងឃ្មុំ
92. កំពង់ឆ្នាំង
93. កំពង់ធំ
94. ស្វាយរៀង
95. កំពត
96. កោះកុង
97. បាត់ដំបង
98. សៀមរាប
99. រតនៈគីរី
100. អង្គការ លីកាដូ (LICADHO)
101. បណ្តាញយុវជនកម្ពុជា (CYN)
102. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
103. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
104. អង្គការ សមធម៌កម្ពុជា (EC)

105. បណ្ដាញកសាងសន្តិភាពសហគមន៍ (CPN)
106. ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន (HRTF)
107. អង្គការ អភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង (UPWD)
108. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
109. អង្គការ សមាគមធាងត្នោត (STT)
110. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF)
111. អង្គការអភិវឌ្ឍន៍សំឡេងសហគមន៍ (BCV)
112. គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគម ការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
113. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
114. អង្គការស្ពានសន្តិភាព (CBO)
115. អង្គការស្ត្រីខ្មែរ (SKO)